# ស្ថានភាពអតិផរណានៅខែធ្នូ និងប្រចាំឆ្នាំ ២០១៥

*******

## ក/ អតិផរណាក្នុងប្រទេស

តាមប្រភពពីវិទ្យាស្ថានជាតិស្ថិតិបង្ហាញថា នៅខែធ្នូ ឆ្នាំ២០១៥ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់នៅភ្នំពេញ បានកើនឡើង 0,២% ធៀបនឹងខែកន្លងទៅ។ ជារួម សម្រាប់ឆ្នាំ២០១៥ អតិផរណាមធ្យមប្រចាំឆ្នាំ (year average) មានកម្រិត ១,២% និងអតិផរណាប្រចាំឆ្នាំ (year on year) មានកម្រិត ២,៨% ។

តាមការសង្កេត អតិផរណានៅឆ្នាំ២០១៥ មានកម្រិតទាបសមស្រប ដោយសារសន្ទស្សន៍ថ្លៃការដឹកជញ្ជូន សន្ទស្សន៍ថ្លៃផ្ទះសំបែង ទឹក អគ្គិសនី ឧស្ម័ននិងឥន្ធនៈដទៃទៀត និងសន្ទស្សន៍ថ្លៃទំនិញនិងសេវាកម្មផ្សេងៗ មានការធ្លាក់ចុះទាប ។ ប៉ុន្តែ សន្ទស្សន៍ថ្លៃទំនិញមួយចំនួនទៀត ក៏មានការកើនឡើងខ្ពស់គួរឲ្យកត់សម្គាល់ដែរ ដូចជាសន្ទស្សន៍ថ្លៃភេសជ្ជៈមានជាតិស្រវឹងនិងថ្នាំជក់កើនឡើងខ្ពស់ដល់ ១០,១% មកពីមានការកែសម្រួលអត្រាអាករពិសេសលើបារីនិងស្រា សន្ទស្សន៍ថ្លៃភោជនីយដ្ឋានកើនឡើងដល់ ៧,៣% សន្ទស្សន៍ថ្លៃអាហារនិងភេជ្ជៈមិនមែនជាតិស្រវឹងកើនឡើង ៥,៥% និងសន្ទស្សន៍ថ្លៃសំលៀកបំពាក់និងស្បែកជើង កើនឡើង ៥,៦% ជាដើម ។ ក្រៅពីនេះគឺស្ថិតនៅក្រោម ៥% ឬ ប្រហាក់ប្រហែលឆ្នាំកន្លងទៅ ។ ការកើនឡើងនេះ ដោយសារការរីកចម្រើនសេដ្ឋកិច្ច ការកើនឡើងចំណាយវិនិយោគសារធារណៈ ព្រមទាំងមានការកើនឡើងតម្រូវការប្រើប្រាស់ជាលក្ខណៈគ្រួសារ ជាពិសេស មានការកើនឡើងលើថ្លៃត្រី សាច់ បន្លែ ដែលផលិតផលទាំងនោះ បានធ្លាក់ចុះដោយសារការប្រែប្រួលអាកាសធាតុ ការប្រកួតប្រជែងខ្ពស់ និងអស្ថេរភាពក្នុងអាជីវកម្ម ជាដើម ។

ការប្រែប្រួលសន្ទស្សន៍ថ្លៃទាំង ១២ ក្រុម មានដូចខាងក្រោម÷

| | ខែមុន | ១២ខែមុន |
|---|---|---|
| មុខទំនិញគ្រប់មុខ | 0,២ | ២,៨ |
| ១-អាហារនិងភេសជ្ជៈមិនមែនជាតិស្រវឹង | 0,៦ | ៥,៥ |
| ២-ភេសជ្ជៈមានជាតិស្រវឹងនិងថ្នាំជក់ | ២,១ | ១០,១ |
| ៣-សំលៀកបំពាក់និងស្បែកជើង | 0,២ | ៥,៦ |
| ៤-ផ្ទះសំបែង ទឹក អគ្គិសនី ឧស្ម័ន និងឥន្ធនៈដទៃទៀត | -0,៥ | -៣,៤ |
| ៥-គ្រឿងសង្ហារឹម សម្ភារៈប្រើប្រាស់ និងការថែទាំ | -0,៦ | ២,៤ |
| ៦-សុខាភិបាល | 0,៤ | ២,0 |
| ៧-ការដឹកជញ្ជូន | -១,៧ | -៧,១ |
| ៨-គមនាគមន៍ | 0,១ | 0,៥ |
| ៩-ការកំសាន្ត និងវប្បធម៌ | ១,៥ | ៣,៧ |
| ១០-ការសិក្សា | 0,0 | 0,៦ |
| ១១-ភោជនីយដ្ឋាន | 0,0 | ៧,៣ |
| ១២-ទំនិញ និងសេវាកម្មផ្សេងៗ | 0,១ | -0,៥ |

## តារាងប្រៀបធៀបបម្រែបម្រួលសន្ទស្សន៍ថ្លៃម្ហូបអាហារមួយចំនួនប្រចាំឆ្នាំ ២០១៤-២០១៥ (%)

| មុខទំនិញ | ២០១៤ | | | | | ២០១៥ | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
| អង្ករ | 1.4 | 1.3 | 1.3 | 1.1 | 1.0 | 2.0 | 2.5 | 2.1 | 2.9 | 2.5 |
| សាច់គោ | 7.3 | 6.9 | 7.1 | 5.6 | 3.7 | 0.6 | 1.3 | 1.7 | 5.1 | 7.9 |
| សាច់មាន់ | 4.5 | 3.9 | 3.2 | 3.6 | 2.8 | 1.9 | 2.2 | 2.5 | 3.6 | 3.8 |
| សាច់ទា | 4.9 | 4.5 | 4.0 | 5.1 | 4.3 | 2.7 | 2.8 | 3.0 | 3.2 | 3.8 |
| សាច់ជ្រូក | 11.1 | 10.1 | 9.2 | 8.8 | 8.1 | 1.0 | 1.1 | 1.1 | 3.5 | 4.8 |
| ត្រីទឹកសាប និង ត្រីទឹកសមុទ្រ | 5.3 | 4.6 | 2.6 | 2.1 | 3.0 | 7.3 | 7.3 | 7.9 | 10.2 | 11.7 |
| ក្នុងនោះត្រីស្រស់ | 5.5 | 4.8 | 2.7 | 1.8 | 3.0 | 8.6 | 8.6 | 8.7 | 11.3 | 13.0 |
| ផ្លែឈើ | 12.4 | 9.7 | 6.3 | 9.5 | 6.0 | 1.1 | 2.0 | 5.2 | 1.9 | 4.3 |
| ផ្លែឈើស្រស់ | 14.5 | 11.3 | 7.0 | 11.0 | 7.3 | 2.1 | 3.2 | 7.2 | 2.9 | 5.1 |
| បន្លែ | 2.6 | 1.6 | -0.2 | 1.2 | 0.0 | 7.4 | 7.6 | 8.6 | 4.8 | 5.5 |
| បន្លែជាស្លឹក | 1.2 | -1.2 | -4.8 | -2.4 | -3.1 | 8.8 | 8.7 | 10.6 | 4.7 | 5.1 |
| បន្លែជាផ្លែ | 8.2 | 7.8 | 7.2 | 10.4 | 6.6 | 10.8 | 12.3 | 10.7 | 4.3 | 5.5 |

ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ

### ខ/ អតិផរណាប្រចាំឆ្នាំរបស់ប្រទេសមួយចំនួន

អត្រាអតិផរណានៅប្រទេសកម្ពុជានៅតែមានស្ថិរភាព គឺមានការប្រែប្រួលជុំវិញអត្រា១% នៅឆ្នាំ២១៥ ប៉ុន្តែអត្រាអតិផរណាងើបឡើងវិញបានរហូតដល់ទៅ ២,៨% នៅចុងឆ្នាំ។ នេះគឺស្រដៀងគ្នាសម្រាប់បណ្តាប្រទេសជិតខាងដូចជាប្រទេសហ្វីលីពីនវៀតណាម និងកូរ៉េខាងត្បូងផងដែលអតិផរណានៅចុងឆ្នាំ បានងើបឡើងពីការធ្លាក់ចុះកាលពីដើមឆ្នាំនិងពាក់កណ្តាលឆ្នាំ២០១៥។ ដូចជាអត្រាអតិផរណានៅប្រទេសហ្វីលីពីនគឺបានធ្លាក់ដល់ ០,៣៥% ខែកញ្ញា ឆ្នាំ២០១៥ ដែលជាអត្រាទាបបំផុតរយៈពេល២ឆ្នាំចុងក្រោយនេះ ប៉ុន្តែបានស្ទុះងើបឡើងវិញរហូតដល់ ១,៥% នៅខែធ្នូ។ ក្នុងនោះសន្ទស្សន៍ថ្លៃអាហារនិងសន្ទស្សន៍ថ្លៃ crude materials, inedible except fuels បានកើនឡើង ១,២% និង ៣,៤% រៀងគ្នា។ អតិផរណានៅក្នុងប្រទេសផ្សេងទៀតដូចជាប្រទេសថៃ ជប៉ុន និងម៉ាឡេស៊ីទោះជាយ៉ាងណានៅតែមានស្ថិរភាពក្នុងអំឡុងពេលចុងឆ្នាំ២០១៥ បើទោះជាមានការប្រែប្រួលនៅដើមឆ្នាំ និងពាក់កណ្តាលឆ្នាំ។ អ្វីដែលគួរឱ្យកត់សម្គាល់គឺនៅឆ្នាំ ២០១៥ ថាអត្រាអតិផរណាថៃបានស្ថិតនៅចំនុចអវិជ្ជមានទូទាំងឆ្នាំ២០១៥ ទោះបីជាមានកិច្ចខិតខំប្រឹងប្រែងពីរដ្ឋាភិបាលក្នុងការជុំរុញសេដ្ឋកិច្ចក្តី។ ការធ្លាក់ចុះនូវតម្រូវការលើសកលលោកបានប៉ះពាល់ដល់វិស័យខាងក្រៅ (external sector) របស់ប្រទេសថៃហើយរួមជាមួយនឹងបំណុលគ្រួសារខ្ពស់ និងការថយចុះនៃទំនុកចិត្តអតិថិជន បានធ្វើអោយសន្ទុះការប្រើប្រាស់មានភាពយឺត។ ផ្ទុយទៅវិញ, អតិផរណានៅឥណ្ឌូនេស៊ីនៅតែមានការប្រែប្រួលប្រៀបធៀបទៅនឹងឆ្នាំ២០១៤ ដែលអត្រាអតិផរណានៅដើមឆ្នាំគឺ៦,៩៦% ហើយបានស្ថិតនៅកម្រិតខ្ពស់ក្នុងអំឡុងឆ្នាំ២០១៥ ប៉ុន្តែបានធ្លាក់ចុះដល់ ៣,៣៥% នៅដំណាច់ឆ្នាំ។ ការប្រែប្រួលនៃអតិផរណានេះហាក់ដូចជាទាក់ទងជាមួយការប្រែប្រួលនៃតម្លៃប្រេងពិភពលោកគឺ ដោយសារតែការកាត់បន្ថយឧបត្ថម្ភធនប្រេងសាំងដែលនាំអោយតម្លៃប្រេងសាំងក្នុងស្រុកប្រែប្រួលស្របគ្នាជាមួយតម្លៃប្រេងសាំងអន្តរជាតិ។

## តារាងឧបសម្ព័ន្ធ៣÷ អតិផរណាប្រចាំឆ្នាំ (ជាភាគរយ)

| ប្រទេស | តារាងឧបសម្ព័ន្ធ÷ អតិផរណាប្រចាំឆ្នាំ(%) | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ២០១៤ | | | | | | | | | | | | ២០១៥ | | | | | | | | | | | |
| | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
| កម្ពុជា | 4.54 | 4.29 | 4.99 | 4.93 | 4.55 | 4.85 | 4.26 | 4.11 | 3.58 | 2.90 | 2.40 | **1.10** | 0.4 | 1.6 | 1.1 | 1.3 | 1.0 | 0.7 | 0.8% | 0.8 | 0.9 | 1.3 | 1.9 | **2.8** |
| វៀតណាម | 5.45 | 4.65 | 4.39 | 4.45 | 4.72 | 4.98 | 4.94 | 4.31 | 3.62 | 3.23 | 2.60 | **1.84** | 0.94 | 0.34 | 0.93 | 0.99 | 0.95 | 1.00 | 0.90 | 0.61 | 0.00 | -0.01 | 0.34 | **0.59** |
| ថៃ | 1.93 | 1.96 | 2.11 | 2.45 | 2.62 | 2.35 | 2.16 | 2.09 | 1.75 | 1.48 | 1.26 | **0.60** | -0.41 | -0.52 | -0.57 | -1.04 | -1.27 | -1.07 | -1.05 | -1.19 | -1.07 | -0.77 | -0.97 | **-0.85** |
| ម៉ាឡេស៊ី | 3.40 | 3.50 | 3.50 | 3.40 | 3.20 | 3.30 | 3.20 | 3.30 | 2.60 | 2.80 | 3.00 | **2.70** | 1.00 | 0.09 | 0.91 | 1.82 | 2.09 | 2.54 | 3.26 | 3.08 | 2.62 | 2.52 | 2.59 | **2.68** |
| ឥណ្ឌូនេស៊ី | 8.22 | 7.75 | 7.35 | 7.25 | 7.32 | 6.70 | 4.53 | 3.99 | 4.53 | 4.83 | 6.23 | **8.36** | 6.96 | 6.29 | 6.38 | 6.79 | 7.15 | 7.26 | 7.26 | 7.18 | 6.83 | 6.25 | 4.89 | **3.35** |
| ភីលីពីន | 4.20 | 4.10 | 3.90 | 4.10 | 4.50 | 4.40 | 4.90 | 4.90 | 4.40 | 4.30 | 3.70 | **2.70** | 2.40 | 2.47 | 2.40 | 2.17 | 1.58 | 1.22 | 0.78 | 0.64 | 0.35 | 0.43 | 1.07 | **1.49** |
| ចិន | 2.50 | 2.00 | 2.40 | 1.80 | 2.50 | 2.30 | 2.30 | 2.00 | 1.60 | 1.60 | 1.40 | **1.50** | -1.66 | -0.59 | -0.98 | -0.29 | -1.27 | -0.88 | -0.68 | 0.00 | 0.00 | -0.30 | 0.10 | **0.10** |
| កូរ៉េខាងត្បូង | 1.10 | 1.00 | 1.30 | 1.50 | 1.70 | 1.70 | 1.60 | 1.40 | 1.10 | 1.20 | 1.00 | **0.80** | 0.83 | 0.55 | 0.37 | 0.37 | 0.55 | 0.64 | 0.64 | 0.64 | 0.59 | 0.92 | 1.01 | **1.30** |
| ជប៉ុន | 1.40 | 1.50 | 1.60 | 3.40 | 3.70 | 3.60 | 3.40 | 3.30 | 3.20 | 2.90 | 2.40 | **2.40** | 2.38 | 2.18 | 2.28 | 0.58 | 0.48 | 0.39 | 0.29 | 0.29 | 0.00 | 0.29 | 0.29 | **0.19** |

កំណត់សម្គាល់÷ ប្រភពទិន្នន័យ(១) ប្រទេសកម្ពុជា គឺពីវិទ្យាស្ថានជាតិស្ថិតិ (២) ប្រទេសផ្សេងៗទៀត គឺពីគេហទំព័រ http://www.tradingeconomics.com

**រៀបចំ និង ធ្វើចំណោលដោយ**

**នាយដ្ឋានស្ថិតិ**

**អគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ច និង ហិរញ្ញវត្ថុសាធារណៈ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**